MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤៩........សហវ.ប្រក

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៧

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់កម្រៃសុំសិទ្ធិ បង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃអ្នកនិពន្ធ អក្សរសាស្ត្រ សិល្បៈ និងតន្ត្រី ដែលគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និង

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ០១ /នស/ ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពី



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០០៣ ប្រកាសឱ្យប្រើ ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែម និងកែ សម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការគ្រប់គ្រងត្រួតពិនិត្យ សិល្បៈ ភាពយន្ត និងវីដេអូ
- បានឃើញសេចក្ដីសំរេច លេខ ១០ សសរ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្ដីពីការបង្កើតគណៈកម្មការអន្តរ ក្រសួងបង្ក្រាបបទល្មើសភាពយន្ត និងវីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃ គណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីការពង្រឹងការ គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ជា ទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្ដីពីវដ្តនេយ្យចំណូល
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## **សម្រេច**

ប្រការ ១ : អនុញ្ញាតឱ្យយកកម្រៃលើការផ្ដល់សិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មាន អ្នកទទួលមរតក ឬ គ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលមានចែង ក្នុងច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

**ប្រការ ២ :** កម្រៃលើការសុំសិទ្ធិស្នាដៃអ្នកនិពន្ធដើម្បីបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក ឬ គ្មានមរតកសាសន៍ ដែលបានចែងក្នុងប្រការ ១ ត្រូវបានកំណត់ដូចតទៅ :

| **ប្រភេទផលិតផលវប្បធម៌សំរាប់ប្រកបអាជីវកម្ម** | **តំលៃ(គិតជារៀល)** |
|---|---|
| **ក- ស្នាដៃអក្សរសាស្ត្រ :** | |
| ផលិតឡើងវិញនូវស្នាដៃវចនានុក្រម ( មួយចំណងជើង) | ៣០០.០០០ |
| ស្នាដៃវចនានុក្រម ផលិតជាកម្មវិធីកុំព្យូទ័រ ( មួយចំណងជើង) | ៤០០.០០០ |
| ផលិតឡើងវិញនូវស្នាដៃមិនមែនវចនានុក្រម ( មួយចំណងជើង) | ១៥០.០០០ |
| ថតខ្សែភាពយន្ត ( មួយរឿង) | ៤០០.០០០ |
| ថតខ្សែវីដេអូ ( មួយរឿង) | ៣២០.០០០ |
| ផលិតជារឿងល្ខោនគ្រប់ប្រភេទ ឬយីកេ | ២០០.០០០ |
| **ខ-ស្នាដៃតូរ្យតន្ត្រី** | |
| ផលិតឡើងវិញនូវតន្ត្រីមានទំនុកច្រៀង ឬគ្មានទំនុកច្រៀង ០១ ( មួយ) បទ | ២០.០០០ |
| ផលិតជាស្នាដៃបន្តនូវតន្ត្រី មានទំនុកច្រៀង ឬគ្មានទំនុកច្រៀង ០១( មួយ) បទ | ២៨.០០០ |
| សម្តែងតន្ត្រីមានទំនុកច្រៀង ឬគ្មានទំនុកច្រៀង ០១ ( មួយ) បទ | ១០.០០០ |
| តូរ្យតន្ត្រីដើមមានទំនុកច្រៀង ឬគ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ីនធឺណែត (វេបសាយ) ០១ ( មួយ) បទ | ៤.០០០ |
| តូរ្យតន្ត្រីបន្តមានទំនុកច្រៀង ឬគ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ីនធឺណែត (វេបសាយ) ០១ ( មួយ) បទ | ៤.០០០ |
| **គ- ស្នាដៃសិល្បៈទស្សនីយភាព** | |
| សម្តែងមួយរឿង | ១០០.០០០ |
| សម្តែងមួយឈុត | ២០.០០០ |
| **ឃ-ស្នាដៃសិល្បៈសូនរូប** | |
| ចម្លាក់ពុម្ពព្រះសិរសា ព្រះបាទជ័យវរ្ម័នទី៧ ខ្នាតតូច ចាប់ពីកំពស់ ០១ ស.ម ទៅ ២០ស.ម | ២០.០០០ |
| ចម្លាក់ពុម្ព ព្រះសិរសា ព្រះបាទជ័យវរ្ម័នទី៧ ខ្នាតធំ ចាប់ពីកំពស់ ២១ ស.ម ឡើងទៅ | ៤០.០០០ |

ប្រការ ៣ : ពាក្យស្នើសុំសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដូចបានចែងក្នុងប្រការ ១ ត្រូវធ្វើឡើងនៅការិយាល័យនីតិកម្ម និងសិទ្ធិអ្នកនិពន្ធ នៃនាយកដ្ឋានរដ្ឋបាលទូទៅ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ប្រការ ៤ : - រាល់ការបង្កើតផលិតផលវប្បធម៌ សំរាប់បម្រើផលប្រយោជន៍សាធារណៈ ដែលមិនប្រកបអាជីវកម្ម ពុំតម្រូវឱ្យបង់ប្រាក់កម្រៃឡើយ ។

- អ្នកដែលបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលមិនបានអនុវត្តទៅតាមច្បាប់ដែលបានកំណត់ និងមិនបានសុំសិទ្ធិអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នោះត្រូវផាកពិន័យ និងត្រូវទទួលទោសទៅតាមច្បាប់ជាធរមាន ។

ប្រការ ៥ : ចំណូលពីការសុំសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលបានចែងក្នុងប្រការ ១ ត្រូវបានអនុវត្តដូចខាងក្រោមនេះ :

- ចំណូលនេះត្រូវប្រមូលដោយការិយាល័យនីតិកម្ម និងសិទ្ធិអ្នកនិពន្ធ នៃនាយកដ្ឋានរដ្ឋបាលទូទៅ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងត្រូវចេញបង្កាន់ដៃទទួលប្រាក់ជូនទៅអតិថិជន ឬផលិតករ ដែលបានបង់ប្រាក់ ។

- ចំណូលពីសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរត ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ត្រូវបង់១០០%ចូលរតនាគារជាតិ តាមរយៈរដ្ឋទេយ្យករចំណូលរបស់ក្រសួង ។

- ការគ្រប់គ្រងចំណូលនេះត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៨ តាមមាតិកាថវិការដ្ឋនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

- ការប្រមូលចំណូលពីការសុំសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលបានចែងក្នុងប្រការ ១ ត្រូវមានសហការចូលរួមផ្ទៀងផ្ទាត់ និងត្រួតពិនិត្យដោយផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបូកសរុប និងធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់ ។

ប្រការ ៦ : បទបញ្ញត្តិ ឬប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវ

ទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨ :** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ហ៊ឹម ឆែម**

**ចម្លងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៧ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ